ខេមបូចា CambojA
សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association
(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

# សេចក្តីប្រកាសព័ត៌មាន

## ការកើនឡើងនៃការគំរាមកំហែង និងចំណាត់ការតាមផ្លូវច្បាប់មកលើអ្នកសារព័ត៌មាននៅកម្ពុជា

**ភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤**– របាយការណ៍ឃ្លាំមើលប្រចាំឆ្នាំ២០២៣ របស់ខេមបូចា ស្តីពីស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជាបានបង្ហាញពីនិន្នាការកើនឡើងនៃវិធានការផ្លូវច្បាប់ ឬការគំរាមកំហែងលើអ្នកសារព័ត៌មាន។

នៅឆ្នាំ២០២៣ យើងបានកត់ត្រាករណីយាយីចំនួន ៣២ករណីមកលើអ្នកសារព័ត៌មានយ៉ាងហោចណាស់ ៥៩នាក់ ក្នុងនោះ ៦នាក់គឺជាអ្នកសារព័ត៌មានស្ត្រី។ បើទោះបីជាករណីយាយីបានធ្លាក់ចុះ ៨,៦ភាគរយធៀបនឹងឆ្នាំ២០២២ ប៉ុន្តែចំនួនអ្នកសារព័ត៌មាន ដែលទទួលរងនូវការយាយីបានកើនឡើង ៩,៣ភាគរយ។

បើធៀបនឹងឆ្នាំ២០២២ ករណីគំរាមកំហែងតាមផ្លូវច្បាប់បានកើនឡើង១១៤ភាគរយ ពីចំនួន៧ករណីដល់ ១៥ករណីនៅឆ្នាំ២០២៣ ក្នុងនោះរួមមានបណ្តឹង ការគំរាមកំហែងតាមផ្លូវច្បាប់ និងការកោះហៅដើម្បីសាកសួរ ដែលបង្កឱ្យមានការព្រួយបារម្ភអំពីលំហរួមតូចសម្រាប់សេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។

អ្នកសារព័ត៌មានយ៉ាងតិច៥នាក់ ត្រូវបានប្តឹង និងចោទប្រកាន់ ដែលឈានដល់ ការជាប់ពន្ធនាគារ ឬការឃុំខ្លួន។ ទាំងនេះមិនត្រឹមតែប៉ះពាល់ដល់អ្នកសារព័ត៌មានដោយផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរឹតត្បិតលើបណ្តាញផ្សព្វផ្សាយព័ត៌មានទាំងមូលផងដែរ។

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជាឬហៅកាត់ថា ខេមបូចា មានប្រសាសន៍ថា "យើងទទួចថា អ្នកសារព័ត៌មានគួរត្រូវបានផ្តល់សេរីភាពក្នុងការបំពេញការងារដើម្បីផ្តល់ព័ត៌មានដល់សាធារណជន និងជំរុញឲ្យអ្នកមានអំណាចទទួលខុសត្រូវ ដោយមិនមានការភ័យខ្លាចពីការគំរាមកំហែងលើរូបរាងកាយ ឬការយាយីតាមផ្លូវច្បាប់នោះទេ"។

ការចោទប្រកាន់ពីបទព្រហ្មទណ្ឌមិនគួរជាជម្រើស ដែលត្រូវប្រើមកលើអ្នកសារព័ត៌មាននោះទេ។ ប៉ុន្តែការគំរាមកំហែងដោយប្រើវិធានការច្បាប់ត្រូវបានប្រើប្រាស់ជាញឹកញាប់មកលើអ្នកសារព័ត៌មាន ហើយការធ្វើបែបនេះអាចនាំឱ្យមានការបំបិទមាត់អ្នកសារព័ត៌មាន និងជំរុញឱ្យមានការចាប់ពិរុទ្ធខ្លួនឯង។ ដូច្នេះ យើងអំពាវនាវដល់រដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធ៖

- បញ្ឈប់ការចោទប្រកាន់បទព្រហ្មទណ្ឌលើអ្នកសារព័ត៌មាន ដោយសារតែពួកគេបំពេញការងារជាអ្នកសារព័ត៌មាន។
- បញ្ចប់និទណ្ឌភាព ដោយធ្វើការស៊ើបអង្កេត កាត់ទោស និងដោះស្រាយករណីអំពើហិង្សាលើអ្នកសារព័ត៌មានភ្លាមៗ។
- ទម្លាក់ចោលភ្លាមៗនូវការចោទប្រកាន់ដែលគ្មានមូលដ្ឋាន ហើយពិនិត្យឡើងវិញនូវការផ្តន្ទាទោសព្រហ្មទណ្ឌលើអ្នកសារព័ត៌មាន។
- ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីឲ្យស្របតាមបទដ្ឋានអន្តរជាតិស្តីពីសេរីភាពនៃការបញ្ចេញមតិ។
- លុបចោលប្រកាសរបស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឲ្យរដ្ឋាភិបាលលុបអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយមិនបានឆ្លងកាត់នីតិវិធីតុលាការ ព្រោះការធ្វើបែបនេះបំពានគោលការណ៍សេរីភាពសារព័ត៌មាន និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។
- លុបចោលប្រកាសអន្តរក្រសួងលេខ១៧០ ដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីលុបអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយគ្មានសេចក្តីសម្រេចពីតុលាការ ហើយដែលបញ្ជាឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណិតបិទគេហទំព័រ។

ខេមបូចា ឈរលើសាមគ្គីភាពជាមួយអ្នកសារព័ត៌មាន ហើយនឹងបន្តជំរុញដើម្បីសុវត្ថិភាពរបស់ពួកគេក៏ដូចជាការពារសេរីភាពសារព័ត៌មាន។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

ទូរស័ព្ទ៖ (+៨៥៥) ១២ ៥១៩ ២៦១ (Signal)

អ៊ីមែល: ed@camboja.net (អង់គ្លេស និងខ្មែរ)

សូមអានរបាយការណ៍ទាំងស្រុងនៅទីនេះ ៖ https://www.camboja.net/cambodian-journalism-situation-report-2023/